medicare



# សាច់រឿងរបស់ Thi

**ក្រុមអាយុ៖** 35-40 ឆ្នាំ

**មុខរបរ៖** ជំនួយការរដ្ឋបាល

**ភាសាដែលនិយាយ៖** អង់គ្លេស/វៀតណាម



**ក្នុងនាមជាម្ដាយវ័យក្មេងដ៏មមាញឹកម្នាក់ Thi Nguyen ដឹងច្បាស់អំពីការចំណាយក្នុងគ្រួសារអាចកើនឡើងយ៉ាងឆាប់រហ័ស។** ទោះបីជាការចាក់ថ្នាំបង្ការជាប្រចាំរបស់កូននាងមិនគិតថ្លៃនៅក្រោមកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិក៏ដោយ ក៏នាងនៅតែមានការព្រួយបារម្ភថាតើថ្លៃសេវាកម្មពិគ្រោះយោបល់របស់ GP នឹងបន្ថែមសម្ពាធដល់ថវិកាគ្រួសាររបស់នាងដែរឬទេ។

ការដឹងថាគ្លីនិក GP ជាច្រើនបានផ្លាស់ប្ដូរទៅការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋពេញលេញ បានផ្ដល់ឱ្យនាងនូវភាពប្រាកដប្រជាបន្ថែមទៀតថាការណាត់ជួបរបស់កូននាងនឹងមិនត្រូវបានគិតថ្លៃអ្វីទាំងអស់។ Thi និយាយថា៖ "GP ពិតជាអស្ចារ្យ ហើយធ្វើឱ្យកូនរបស់ខ្ញុំមានអារម្មណ៍សុខស្រួលណាស់។ សំខាន់បំផុត គឺថាខ្ញុំមិនដែលឃើញវិក្កយបត្រទេ។ Medicare បានបង់ប្រាក់ឱ្យវេជ្ជបណ្ឌិតដោយផ្ទាល់ ដូច្នេះមិនមានការចំណាយផ្ទាល់ចេញពីហោប៉ៅទេ។"

សម្រាប់ Thi ការគាំទ្រនេះមានន័យថា នាងមិនត្រូវពន្យារការថែទាំសុខភាពរបស់កូននាងឡើយ។

> *នាងពន្យល់ថា៖ "ការដឹងថាការទៅពិនិត្យទាំងនេះត្រូវបានគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ ផ្ដល់ឱ្យខ្ញុំនូវភាពស្ងប់ចិត្ត។ វាអនុញ្ញាតឱ្យខ្ញុំផ្ដល់អាទិភាពដល់សុខភាពកូនរបស់ខ្ញុំ ដោយមិនខ្វល់ព្រួយអំពីថវិកាគ្រួសារ។ វាជាវិធីសាមញ្ញ ហើយមានតម្លៃសមរម្យក្នុងការរក្សាកូនរបស់យើង និងសហគមន៍របស់យើងឱ្យមានសុវត្ថិភាព។"*
>
> **- Thi**

ស្កេនកូដ QR នេះសម្រាប់ព័ត៌មានបន្ថែម

ដើម្បីស្វែងរកវេជ្ជបណ្ឌិតដែលគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ **health.gov.au/bulkbilling**

Australian Government
Department of Health, Disability and Ageing